**ព្រះរាជាណាចក្រកម្ពុជា**

រាជរដ្ឋាភិបាលកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ១៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលព្រំប្រទល់រដ្ឋបាល និងការប្តូរស្រុកស្ទឹងសែន ទៅជាក្រុងស្ទឹងសែន នៃខេត្តកំពង់ធំ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង សុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## សម្រេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលព្រំប្រទល់រដ្ឋបាលរវាង ស្រុកស្ទឹងសែន ស្រុកសន្ទុក និង ស្រុកកំពង់ស្វាយ នៃខេត្តកំពង់ធំ ដោយកាត់យកឃុំចំនួនបីចេញពីស្រុកស្ទឹងសែន គឺ ឃុំត្បូងក្រពើ បញ្ចូលទៅក្នុងស្រុកសន្ទុក ឃុំក្ដីដូង និង ឃុំព្រៃគុយ បញ្ចូលទៅក្នុងស្រុកកំពង់ស្វាយ នៃខេត្តកំពង់ធំ។

**មាត្រា ២.-**

ត្រូវបានប្តូរស្រុកស្ទឹងសែន ទៅជា **ក្រុងស្ទឹងសែន** នៃខេត្តកំពង់ធំ ។

ព្រំប្រទល់រដ្ឋបាលនៃ **ក្រុងស្ទឹងសែន** ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ៣.-**

ត្រូវបានប្តូរ ឃុំចំនួនប្រាំបីនៃ **ក្រុងស្ទឹងសែន** ឱ្យទៅជាសង្កាត់ ដូចមានខាងក្រោម :

| | | |
|---|---|---|
| ១- ឃុំកំពង់រទេះ | ទៅជា | សង្កាត់កំពង់រទេះ |
| ២-ឃុំកំពង់ធំ | ទៅជា | សង្កាត់កំពង់ធំ |
| ៣- ឃុំដំរីជាន់ខ្លា | ទៅជា | សង្កាត់ដំរីជាន់ខ្លា |
| ៤-ឃុំអូរកន្ធរ | ទៅជា | សង្កាត់អូរកន្ធរ |
| ៥-ឃុំកំពង់ក្របៅ | ទៅជា | សង្កាត់កំពង់ក្របៅ |
| ៦-ឃុំព្រៃតាហ៊ូ | ទៅជា | សង្កាត់ព្រៃតាហ៊ូ |
| ៧-ឃុំអាចារ្យលាក់ | ទៅជា | សង្កាត់អាចារ្យលាក់ |
| ៨-ឃុំស្រយ៉ូវ | ទៅជា | សង្កាត់ស្រយ៉ូវ |

**មាត្រា ៤.-**

ត្រូវផ្ទេរទីតាំងសាលាស្រុកស្ទឹងសែន ដែលស្ថិតនៅក្នុងសង្កាត់កំពង់រទេះ ទៅជាសាលា **ក្រុងស្ទឹងសែន** ។

**មាត្រា ៥.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល **ក្រុងស្ទឹងសែន** ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តកំពង់ធំ អភិបាលក្រុងស្ទឹងសែន អភិបាលស្រុកសន្ទុក អភិបាលស្រុកកំពង់ស្វាយ និងក្រុមប្រឹក្សាឃុំ សង្កាត់ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ